**គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា**
**CAMBODIAN HUMAN RIGHTS ACTION COMMITTEE**
ADHOC - CARAM - CCPCR - CDP - CHHRA - CKIMHRDA - CSD - CWCC - GENEROUS - HROTP
IDA - KID - KIND - KKKHRA - KKKHRDA - KSA - KYA - LAC - PDP- PJJ - VIGILANCE
#9, St.330, Boeng Keng Kong III, Chamcar Morn, P.P Tel/Fax: (023) 218 759, Tel: 30 14 15, E-mail: chrac@forum.org.kh, chracsecretariat@yahoo.com

# សេចក្តីថ្លែងការណ៍

## ការព្រួយបារម្ភជុំវិញបញ្ហាទំនាស់ដីធ្លី នៅឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ ជាមួយក្រុមហ៊ុនវៀតណាម

គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា ដែលជាសម្ព័ន្ធអង្គការ-សមាគមមិនមែនរដ្ឋាភិបាលក្នុងស្រុក ចំនួន ២១ មានការសោកស្តាយ និង ព្រួយបារម្ភជាខ្លាំង ជុំវិញបញ្ហាអំពើហិង្សា ដែលបានកើតឡើងកាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៩ បានបណ្តាលឱ្យប្រជាពលរដ្ឋយ៉ាងហោចណាស់ ៩ នាក់រងរបួស ចាប់ខ្លួន ចំនួន ៧ នាក់ និងមានប្រជាពលរដ្ឋមួយចំនួនផ្សេងទៀតត្រូវបានសមត្ថកិច្ចកំពុងស្វែងរកចាប់ខ្លួន ព្រមទាំងធ្វើអោយទ្រព្យសម្បត្តិមួយចំនួន ទទួលរងនូវការខូចខាត។

យោងតាមការចុះពិនិត្យជាក់ស្តែងដល់កន្លែងកើតហេតុបានរកឃើញថា បន្ទាប់ពីមានអំពើហិង្សាកើតឡើង សមត្ថកិច្ចចំរុះប្រមាណ ជាង ៧0 នាក់ បានដាក់ពង្រាយ និង ឡោមពទ្ធ័ ព្រមទាំងបិទផ្លូវប្រជាពលរដ្ឋមិនឱ្យចេញ-ចូល ដើម្បីឆែកឆេរកមុខសញ្ញាចាប់ខ្លួន ដែលធ្វើឱ្យស្ថានភាពប្រជាពលរដ្ឋរស់នៅក្នុងតំបន់នោះ ទទួលរងនូវការភ័យខ្លាចយ៉ាងខ្លាំង។ រហូតមកដល់ពេលនេះ មានប្រជាពលរដ្ឋចំនួន ៧ នាក់ហើយត្រូវបានសមត្ថកិច្ចចាប់ខ្លួន ដោយចោទប្រកាន់ពីបទ បំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈ ក្នុងនោះមានប្រជាពលរដ្ឋចំនួន ៤ នាក់ត្រូវបានសមត្ថកិច្ចចាប់ខ្លួនបាននៅក្នុងទឹកដីខេត្តកំពង់ចាម។

គណៈកម្មាធិការប្រព្រឹត្តិកម្មកត់សំគាល់ឃើញថា ទំនាស់ដីធ្លីនៅចំណុចបន្ទាយរង្សៀង កើតមានឡើងចាប់តាំងពីមានវត្តមានក្រុមហ៊ុនវៀតណាមមួយ ឈ្មោះ **តាន់ បៀន** (Tan Bien Kampong Thom Aphivath Caoutchouc Co, Ltd) ដែលទទួលបានដីសម្បទានសេដ្ឋកិច្ចពីរាជរដ្ឋាភិបាលកម្ពុជា ទំហំ ៨១00 ហិចតា នៅឆ្នាំ២00៧ ដើម្បីអភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្មដាំកៅស៊ូនៅទីនោះ ហើយមិនមានការដោះស្រាយឱ្យបានត្រឹមត្រូវពីអាជ្ញាធរមូលដ្ឋាន និងមិនបានចុះទៅធ្វើការសិក្សាពីផលប៉ះពាល់ជាមុនទេ មុននឹងផ្តល់សម្បទានដីទៅឱ្យក្រុមហ៊ុន ព្រោះការចូលមកកាន់កាប់ដីរបស់ប្រជាពលរដ្ឋកើតមានតាំងពី ឆ្នាំ២00៤ មកម្លេះ តាមរយៈសមាគមយោធិនពិការអភិវឌ្ឍន៍កសិកម្ម ដែលបានបែងចែកដីជូនពួកគាត់ គឺមកនៅមុនក្រុមហ៊ុន **តាន់ បៀន**។

គណៈកម្មាធិការប្រព្រឹត្តិកម្មជឿជាក់ថា ការដោះស្រាយដីធ្លីដែលបានធ្វើកន្លងមកនេះ រវាងប្រជាពលរដ្ឋជាមួយក្រុមហ៊ុន **តាន់ បៀន** មិនបានអនុវត្តទៅតាមភាពជាក់ស្តែង នៃការរស់នៅរបស់ប្រជាពលរដ្ឋទេ ហើយគោលការណ៍ដោះដូរដីធ្លីរបស់សមត្ថកិច្ចមិនអាចធ្វើឱ្យប្រជាពលរដ្ឋទទួលយកបាន ដោយសារតំបន់ដីដែលត្រូវដោះដូរស្ថិតនៅ

ឆ្ងាយ និង មានទំហំដីតូច ខ្វះលក្ខខណ្ឌក្នុងការផ្តល់ដីភោគៈ ។ ម្យ៉ាងទៀតអាជ្ញាធរបានការបង្ករភាពភ័យខ្លាចនានាដល់ប្រជាពលរដ្ឋ ក្នុងនោះមានការបាញ់ គំរាមកំហែង ការលួចដុតបំផ្លាញផ្ទះសំបែងប្រជាពលរដ្ឋ ការមិនអនុញ្ញាតឱ្យប្រជាពលរដ្ឋធ្វើដំណើរចេញ-ចូល ដោយសេរី គឺជាការបង្កឱ្យមានភាពតានតឹងកាន់តែធ្ងន់ធ្ងរឡើងៗ ក្នុងតំបន់ដីទំនាស់នោះ ។

**ដើម្បីដោះស្រាយករណីនេះឱ្យបានឆាប់ និង អាចទទួលយកបាន គណៈកម្មាធិការប្រព្រឹត្តិកម្ម សូមសំណូមពរ និង អំពាវនាវដល់រាជរដ្ឋាភិបាល អាជ្ញាធរខេត្ត និង អាជ្ញាធរមានសមត្ថកិច្ច គ្រប់ជាន់ថ្នាក់ ដូចខាងក្រោមៈ**

-បញ្ឈប់ការប្រើកំលាំងប្រដាប់អាវុធក្នុងការបង្ក្រាបដោយហិង្សាលើប្រជាពលរដ្ឋ និងស្នើសុំឱ្យបើកផ្លូវឱ្យប្រជាពលរដ្ឋមានលទ្ធភាពចេញ-ចូលនៅក្នុងតំបន់នោះ ។

-បញ្ឈប់ជាបន្ទាន់នូវការតាមចាប់ខ្លួនតំណាងប្រជាពលរដ្ឋ និង ការគំរាមកំហែងតាមគ្រប់រូបភាព

-ដោះលែងតំណាងប្រជាពលរដ្ឋ ដែលត្រូវបានចាប់ខ្លួន និងកំពុងឃុំខ្លួនឱ្យមានសេរីភាពឡើងវិញ

-ដោះស្រាយដីធ្លីជូនប្រជាពលរដ្ឋរងគ្រោះក្រីក្រទាំងនោះឱ្យបានឆាប់រហ័ស និង យុត្តិធម៌ ដែលអាចទទួលយកបាន ឬឱ្យពួកគាត់អភិវឌ្ឍន៍នៅនឹងកន្លែង ដោយដាំកៅស៊ូលើដីរបស់ខ្លួន ហើយលក់ផលិតផលឱ្យក្រុមហ៊ុន ។

-សុំឱ្យមានការចរចារជាក់ស្តែង ទល់មុខគ្នា រវាង អាជ្ញាធរមានសមត្ថកិច្ច និង ប្រជាពលរដ្ឋ ។

-បង្កើតគណៈកម្មការចំរុះឯករាជ្យមួយ ដើម្បីដោះស្រាយករណីនេះ ។

ភ្នំពេញ, ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩


សំរាប់ព័ត៌មានបន្ថែមសូមទាក់ទងៈ

| | | |
|---|---|---|
| -លោក **ហង្ស ឆាយា** | ប្រធានសំរបសំរួលគណៈកម្មាធិការប្រព្រឹត្តិកម្ម **CHRAC** | |
| | និង នាយកប្រតិបត្តិ **KID** | **Tel**: ០១២ ៨៦៥ ៩១០ |
| -លោក **ធន សារាយ** | ប្រធាន សមាគមអាដហុក **ADHOC** | **Tel**: ០១៦ ៨៨០ ៥០៩ |
| -លោក **សុក សំអឿន** | នាយកប្រតិបត្តិ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា **CDP** | **Tel**: ០១២ ៩០១ ១៩៩ |
| -លោកស្រី **ស៊ុន ចាន់សែន** | នាយិកាប្រតិបត្តិសមាគមយុវជនខ្មែរ **KYA** | **Tel**: ០១៧ ៧៨៨ ៩៥៥ |